# រឿង

# កូនទាចេះកែខ្លួនឱ្យល្អ



ឆ្នាំ ២០១០

មានកូនទាមួយឈ្មោះ កេប កេប មិនសូវស្ដាប់បង្គាប់ពុកម៉ែទេ។

ថ្ងៃមួយ ពុកម៉ែចេញទៅរកចំណី និងរកទឹកឱ្យកេបកេបហូបបានប្រាប់ កេប កេប ឱ្យនៅចាំផ្ទះ។

ពុកម៉ែ ចេញទៅបាត់ កេប កេប ចេញដែរ ។



កេប កេប រត់លេងកន្លែងនេះបន្តិច កន្លែងនោះបន្តិច។ វាស្រេកទឹកណាស់។



កេប កេប ទៅសុំទឹក គីគី ហូប។ គីគី មិន
ព្រមឱ្យទឹកវាហូបទេ។



កេប កេប ភ័យណាស់ អង្គុយយំម្នាក់ឯង។



ជួនពេលនោះ កេប កេប ក្រឡេកឃើញ ទាព្រៃមួយហ្វូងហើរសំដៅទៅទិសខាងជើង។ កេបកេបក៏ខំប្រឹងទទះស្លាបហើរទៅតាមគេ។



ទៅដល់កន្លែងមួយ មានទឹកពណ៌ខៀវស្រងាត់ កេបកេប ក៏ហើរសំដៅចុះទឹកនោះ។ វាប្រុងហូបទឹកឱ្យបានច្រើនតាមការស្រេកឃ្លានរបស់វា។ តែវាបានស្ទុះងើបឡើងយ៉ាងរហ័ស ដោយទឹកនោះមានជាតិប្រៃ។



កេប កេប ប្រឹងហើរដល់មាត់ច្រាំង។ វាចង់ត្រឡប់ទៅផ្ទះវិញ។ តែវាហើរពុំរួចសោះ វាអស់កម្លាំងណាស់។ វាប្រឹងដើរតេះតះៗ យ៉ាងលំបាកសំដៅទៅផ្ទះ។ ដល់ពាក់កណ្ដាលផ្លូវយប់ក៏មកដល់។ វាចូលសម្រាកក្រោមដើមឈើមួយដើមនៅទីនោះ។



ពុកម៉ែរកចំណីបានផ្ញើកូនហើយ តែរកកូនមិនឃើញសោះ ភ័យណាស់ គាត់ក៏អុចចង្កៀងដើររកកេបកេប។ ពុកម៉ែ កេបកេប ឃើញកេបកេបដេកស្ដឹកក្រោមដើមឈើមួយធំ។ ឃើញដូច្នោះ គាត់ក៏ស្ទុះទៅលើកបីកេបកេបឡើង។ កេបកេប ឃើញពុកម៉ែក៏ស្ទុះមកឱបពុកម៉ែវិញភ្លាម ព្រមទាំងយំអង្វរសុំទោសទៀតផង។ កេបកេប សម្រាកស្កប់ស្កល់លើរង្វង់ដៃឪពុកដោយឥតដឹងថា ឪពុកយកខ្លួនដាក់ឱ្យដេកសម្រាកលើផ្ទះផង។ ស្អែកឡើង កេបកេប និយាយពីការលំបាករបស់ខ្លួនពេលចេញពីផ្ទះ ព្រោះតែពុំព្រមស្ដាប់បង្គាប់ពុកម៉ែតាំងពីដើមរហូតដល់ចប់។





តាំងពីពេលនោះមក កេបកេប រាងចាលលែងចេញដើរឆ្ងាយពីផ្ទះទៀតហើយ កេបកេបព្រមស្ដាប់បង្គាប់ពុកនិងម៉ែជានិច្ច។ កេបកេប ក្លាយជាកូនល្អហើយមានមិត្តជាច្រើនស្រឡាញ់រាប់អានកេបកេប។

អ្នកនិពន្ធ : លោកស្រី តឹក ស៊ីផុន

អ្នករៀបរៀង : លោកស្រី ឈុំ សារ៉ានី

វិចិត្រករ : លោក អ៊ុត រឿន

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ សេចក្ដីសម្រេចលេខ ១៣៨ អរ.សសរ.

ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យ

**គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ**

បោះពុម្ពលើកទី១ ចំនួន៥,០០០ក្បាល

រោងពុម្ពក្រសួងអប់រំ ឆ្នាំ១៩៩១

**អំណោយ អ៊ុយនីសេហ្វ**

DON DE L'UNICEF

បោះពុម្ពលើកទី២ដោយ : អង្គការគាំពារកុមារខ្មែរ (CYK)

ភ្នំពេញ ខែកក្កដា ឆ្នាំ២០១០

មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រៃសណីយ៍ជប៉ុនសម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ

ចំនួន : ៥,០០០ក្បាល

លេខ : CYK N10007

រោងពុម្ព : **J S R C** Printing House

**ក្រសួងអប់រំ យុវជន និងកីឡា**

**នាយកដ្ឋានអប់រំកុមារតូច**

CYK

This aid project is supported by all participants in Japan's
Postal Saving for International Voluntary Aid.
និងអង្គការគាំពារកុមារខ្មែរ ( CYK )

9789996351655